ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា



# ក្របខ័ណ្ឌយុទ្ធសាស្ត្រ

## ស្តីពី

## កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៥

# មាតិកា

**សេចក្តីផ្តើម** ទំព័រ១

**I ប្រព័ន្ធគ្រប់គ្រងនាពេលបច្ចុប្បន្ន**

១-ខ្លឹមសារនៃរដ្ឋធម្មនុញ្ញ ទំព័រ២

២-ប្រព័ន្ធគ្រប់គ្រងនៅថ្នាក់ក្រោមជាតិនាពេលបច្ចុប្បន្ន ទំព័រ២

៣-ស្ថានភាពទូទៅនៃការគ្រប់គ្រងនៅថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ទំព័រ៣

**II ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា**

១-ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការរៀបចំប្រព័ន្ធគ្រប់គ្រងនៅថ្នាក់រដ្ឋបាល ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ទំព័រ៦

២-គោលការណ៍ជាមូលដ្ឋានសំរាប់កំណែទំរង់វិមជ្ឈការ និង វិសហមជ្ឈការ ទំព័រ៨

៣-វិធីសាស្ត្រនៃការអនុវត្តកំណែទំរង់ ទំព័រ១០

**III យុទ្ធសាស្ត្រវិមជ្ឈការ និង វិសហមជ្ឈការរបស់រាជរដ្ឋាភិបាលកម្ពុជា**

១-វិសាលភាពនៃយុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការ ទំព័រ១០

២-បណ្តាគោលដៅ និង អាទិភាពនៃយុទ្ធសាស្ត្រវិមជ្ឈការ និង វិសហមជ្ឈការ ទំព័រ១១

៣-ខ្លឹមសារជាមូលដ្ឋានក្នុងការកែទំរង់ ទំព័រ១៣

៤-ការប្រែប្រួលអំពីការគ្រប់គ្រងថ្នាក់រដ្ឋបាលក្រោមជាតិ ទំព័រ១៥

៥-ការកំណត់បែងចែកភារកិច្ច និងការទទួលខុសត្រូវរវាងបណ្តា

ថ្នាក់រដ្ឋបាល ទំព័រ២២
៦-ការកំណត់ចំណូល និងថវិកានៅតាមបណ្ដាថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ទំព័រ២៣
**IV កម្មវិធីជាតិសំរាប់អនុវត្តយុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការ**
១-សមាសភាគ និង លទ្ធផលរំពឹងទុកនៃកម្មវិធីជាតិ ទំព័រ២៥
២-ការគ្រប់គ្រងកម្មវិធី ទំព័រ២៨
៣-ការសាងភាពជាដៃគូ ទំព័រ៣២
៤-វិធានការក្នុងដំណាក់កាលអន្តរកាល ទំព័រ៣៤

## សេចក្តីផ្តើម

ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទំរង់វិមជ្ឈការ និង វិសហមជ្ឈការ គឺជាឯកសារគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលបង្ហាញអំពីចក្ខុវិស័យ និង គោលការណ៍ជាមូលដ្ឋានរបស់រាជរដ្ឋាភិបាល សំរាប់ដឹកនាំដំណើរការកំណែទំរង់អភិបាលកិច្ចនៅថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ។

ឯកសារគោលនយោបាយនេះ នឹងកំណត់អំពីគោលដៅនៃ យុទ្ធសាស្ត្រជាតិ ក្នុងកំណែទំរង់ វិមជ្ឈការ និង វិសហមជ្ឈការ និង អំពីរបៀបរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងនៅតាមបណ្តាថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ដើម្បីអនុវត្តអោយបានសំរេចនូវគោលដៅនៃយុទ្ធសាស្ត្រស្តីពីកំណែទំរង់វិមជ្ឈការ និង វិសហមជ្ឈការ ។

ទន្ទឹមនេះឯកសារនេះក៏នឹងពិពណ៌នាអំពីវិសាលភាពនៃកម្មវិធីជាតិសំរាប់អនុវត្តយុទ្ធសាស្ត្រ វិមជ្ឈការ និង វិសហមជ្ឈការ ព្រមទាំងរចនាសម្ព័ន្ធសំរាប់គ្រប់គ្រងកម្មវិធីនេះផងដែរ ។

ឯកសារយុទ្ធសាស្ត្រនេះ គឺជាឯកសារក្របខ័ណ្ឌការងារសំរាប់ណែនាំដល់ការងារកំណែទំរង់ទាំងអស់ ដែលមានផលប៉ះពាល់ដល់ប្រព័ន្ធគ្រប់គ្រងនៅតាមបណ្តាថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ។ គោលនយោបាយ លិខិតបទដ្ឋាន និង ទំរង់ការទាំងឡាយរបស់បណ្តាក្រសួងស្ថាប័ននានានៃរាជរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងការគ្រប់គ្រង ការបែងចែកភារកិច្ចទទួលខុសត្រូវ និង ធនធានដល់បណ្តាថ្នាក់ ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ត្រូវតែមានសង្គតិភាពជាមួយនឹងគោលដៅ និង គោលការណ៍នៃយុទ្ធសាស្ត្រវិមជ្ឈការ និង វិសហមជ្ឈការ ដើម្បីសំរួលដល់ការ រៀបចំប្រព័ន្ធ និង រចនាសម្ព័ន្ធគ្រប់គ្រង ។ ព្រមជាមួយនេះ

ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះក៏ជាឯកសារគោលសំរាប់បែងចែកអំណាច និង ភារកិច្ចរវាងបណ្តាថ្នាក់រដ្ឋបាល ។

## I-ប្រព័ន្ធគ្រប់គ្រងនាពេលបច្ចុប្បន្ន :

### ១-ខ្លឹមសារនៃរដ្ឋធម្មនុញ្ញ :

តាមខ្លឹមសាររដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ប្រទេសកម្ពុជា ជារដ្ឋទោល ។ទឹកដីនៃព្រះរាជាណាចក្រកម្ពុជា បែងចែកជាខេត្ត និង ក្រុង ។ ខេត្តចែកជាស្រុក ស្រុកចែកជាឃុំ ។ ក្រុងចែកជាខណ្ឌ ខណ្ឌចែកជាសង្កាត់ ។ ប្រទេសកម្ពុជាមាន ២០ ខេត្ត និង ៤ ក្រុង មាន ១៧១ ស្រុក និង ១៤ ខណ្ឌ មាន ១.៥១០ ឃុំ និង ១១១ សង្កាត់ ។

ជំពូកទី១៣ មាត្រា ១៤៦ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា បានចែងថា " ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ត្រូវគ្រប់គ្រងតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់រៀបចំអង្គការមួយ " ។ ច្បាប់អង្គការដែលកំពុងរៀបចំត្រូវឆ្លុះបញ្ចាំងអំពីយុទ្ធសាស្ត្រជាតិ ស្តីពីវិមជ្ឈការ និង វិសហមជ្ឈការ ដែលបានកំណត់ក្នុងឯកសារនេះ ។ ច្បាប់នេះក៏ជាក្របខ័ណ្ឌ គតិយុត្តិជាមូលដ្ឋាន សំរាប់អនុវត្តយុទ្ធសាស្ត្រស្តីពីវិមជ្ឈការ និង វិសហមជ្ឈការផងដែរ ។

### ២-ប្រព័ន្ធគ្រប់គ្រងនៅថ្នាក់ក្រោមជាតិនាពេលបច្ចុប្បន្ន :

បច្ចុប្បន្នប្រព័ន្ធគ្រប់គ្រងនៅថ្នាក់ក្រោមជាតិ ត្រូវបានបែងចែកជា ៣ ថ្នាក់ គឺ : ថ្នាក់ខេត្ត ក្រុង ថ្នាក់ស្រុក ខណ្ឌ និង ថ្នាក់ឃុំ សង្កាត់ ។

-នៅថ្នាក់ស្រុក ខណ្ឌ និង ថ្នាក់ខេត្ត ក្រុង យើងបានដាក់អោយដំណើរការបណ្តាមន្ទីរ ឬអង្គភាព ដែលជាខ្សែរយៈបណ្តោយរបស់ថ្នាក់ជាតិ

នៅតាមថ្នាក់នីមួយៗ ។ កិច្ចការរបស់មន្ទីរ ឬអង្គភាពទាំងនោះ ត្រូវបានសំរបសំរួលដោយតំណាងរបស់រាជរដ្ឋាភិបាល គឺ អភិបាលខេត្ត ក្រុង និង អភិបាលស្រុក ខណ្ឌ ។

-នៅថ្នាក់ឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានបង្កើតឡើង តាមការបោះឆ្នោតដោយផ្ទាល់ ក្នុងលក្ខណៈសេរី ត្រឹមត្រូវ និង យុត្តិធម៌ (ខែកុម្ភៈ ឆ្នាំ ២០០២ ) ។

៣. **<u>ស្ថានភាពនៃការគ្រប់គ្រងនៅថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់</u> :**

ក-<u>នៅថ្នាក់ខេត្ត ក្រុង</u>: ប្រព័ន្ធគ្រប់គ្រងមានលក្ខណៈប្រមូលផ្តុំដោយ មន្ទីរជំនាញ គឺជាអ្នកអនុវត្ត គោលនយោបាយ និង ផែនការតាមខ្សែរយៈ បណ្តោយរបស់បណ្តាក្រសួង និង ស្ថាប័ននៅថ្នាក់ជាតិ ។ ប្រព័ន្ធគ្រប់គ្រង នេះ ត្រូវកាត់ផ្តាច់ជាដុំៗ តាមខ្សែរយៈបណ្តោយរបស់ខ្លួន ការសំរបសំរួល សកម្មភាពតាមខ្សែរយៈទទឹងនៅថ្នាក់ខេត្ត ក្រុងជួបការលំបាកជាច្រើន ។ ប្រព័ន្ធគ្រប់គ្រងនេះ ពុំមានសង្គតិភាពក្នុងប្រព័ន្ធផែនការ ប្រព័ន្ធថវិកា និង ប្រព័ន្ធគ្រប់គ្រងបុគ្គលិកតាមថ្នាក់ខេត្ត ក្រុងនៅឡើយ ។

ក្នុងនាមជាតំណាងរាជរដ្ឋាភិបាល អភិបាលខេត្ត ក្រុង មានភារកិច្ច ថែរក្សាសន្តិសុខ និង សណ្តាប់ធ្នាប់សង្គម ព្រមទាំងទទួលអំណាច ប្រតិភូកម្មពីថ្នាក់ជាតិ ក្នុងការគាំទ្រ និង ពិនិត្យនីត្យានុកូលភាព សកម្មភាពរបស់ឃុំ សង្កាត់ ។ លើសពីនេះ ក៏មានភារកិច្ចសំរបសំរួល ជំរុញ និង តំរង់ ទិសដៅការងាររបស់ បណ្តាមន្ទីរក្នុងខេត្ត ក្រុង ស្របតាមគោល នយោបាយរបស់រាជរដ្ឋាភិបាលផងដែរ ។ ប៉ុន្តែទោះជាយ៉ាងនេះ ក៏ដោយ ក៏ក្នុងការដាក់ស្តែងកន្លងមកកម្មវិធីអភិវឌ្ឍន៍តាមវិស័យជាច្រើនត្រូវបាន

រៀបចំ និង គ្រប់គ្រងតាម របៀបប្រមូលផ្ដុំ ។ មន្ទីរជំនាញតាមខេត្ត ក្រុង មានភារកិច្ចអនុវត្តផ្ទាល់ ហើយត្រូវទទួលខុសត្រូវចំពោះក្រសួង និង ស្ថាប័ននៅថ្នាក់ជាតិ ដែលជាខ្សែរយៈបណ្ដោយរបស់ខ្លួន ។ ភារកិច្ច និង វចនាសម្ព័ន្ធជាន់គ្នាខ្លះៗ ដែលជាហេតុបង្កអោយមានការលំបាកក្នុងការ សំរបសំរួលនៅថ្នាក់នេះ ។ ក្នុងពេលដែលមិនទាន់មានក្របខ័ណ្ឌ គតិយុត្តិ សំរាប់បង្កើត " ប្រព័ន្ធរដ្ឋបាលឯកភាព " ធ្វើអោយខេត្ត ក្រុង មិនអាច បំពេញភារកិច្ចក្នុងការរៀបចំ ផែនការ ថវិកា និង ការគ្រប់គ្រងបុគ្គលិក ព្រមទាំងសំរបសំរួលការផ្ដល់សេវា និង ការអភិវឌ្ឍន៏អោយបានពេញ លេញនៅឡើយ ។

ខ-<u>នៅថ្នាក់ស្រុក.ខណ្ឌ</u>: ជាទូទៅមានភាពទន់ខ្សោយក្នុងការសំរប សំរួល និង ការគ្រប់គ្រង ។ ប្រព័ន្ធគណនេយ្យភាពត្រូវបានអនុវត្តតាមខ្សែ រយៈបណ្ដោយរបស់វិស័យនីមួយៗ ។ ក្រសួង និង ស្ថាប័នខ្លះពុំមាន ការិយាល័យរបស់ខ្លួននៅថ្នាក់ស្រុក ខណ្ឌនៅឡើយ ។ រីឯខ្លះទៀត បាននឹង កំពុងប្រតិបត្តិការក្រៅរង្វង់រដ្ឋបាល ស្រុក ខណ្ឌ ។ បញ្ហាមួយទៀត ដែលបានកើតឡើង គឺ កង្វះសង្គតិភាពរវាងរង្វង់ប្រតិបត្តិការក្នុងការផ្ដល់ សេវាសាធារណៈរបស់ក្រសួង និង ស្ថាប័នមួយចំនួននៅថ្នាក់ស្រុក ខណ្ឌ ជាមួយនឹងព្រំប្រទល់រដ្ឋបាលរបស់ស្រុក ខណ្ឌ ។ ទំហំខុសគ្នាពីស្រុកមួយ ទៅស្រុកមួយក៏បានបង្កការលំបាកក្នុងការផ្ដល់សេវាសំខាន់ៗជាមូលដ្ឋាន អោយមានប្រសិទ្ធភាព ពិសេសសេវាខាងផ្នែកសង្គមកិច្ច ។ ដូចនេះ ការ បង្កើនប្រសិទ្ធភាព ក្នុងការផ្ដល់សេវា សាធារណៈនៅថ្នាក់ស្រុក ខណ្ឌ តំរូវអោយបង្កើតនូវយន្ដការមួយ ដោយត្រូវគិតគូរអោយបានហ្មត់ចត់អំពី បញ្ហា គណនេយ្យភាពរបស់ស្រុក ខណ្ឌ ចំពោះប្រជាពលរដ្ឋផងដែរ ។

គ-នៅថ្នាក់ឃុំ សង្កាត់ ៖ ក្រុមប្រឹក្សាឃុំ សង្កាត់បានដំណើរការជាង ៣ ឆ្នាំកន្លងមក ដោយបាន ដំណើរការរៀបចំ និង អនុវត្តផែនការ និង ថវិកាឃុំ សង្កាត់ ។ ទោះបីជាក្រុមប្រឹក្សាឃុំ សង្កាត់បានទទួលមុខងារផ្ទាល់ក្នុងក្របខ័ណ្ឌច្បាប់អង្គការក៏ដោយ ប៉ុន្តែក្នុងការជាក់ស្តែងរដ្ឋបាលឃុំ សង្កាត់មិនទាន់បានទទួល ភារកិច្ចជាផ្លូវការ ក្នុងការផ្តល់សេវាដល់ប្រជាពលរដ្ឋនៅឡើយ ។ រីឯមុខងារជាភ្នាក់ងារ រដ្ឋបាលឃុំ សង្កាត់ ទើបតែបានទទួលភារកិច្ចក្នុងការចុះបញ្ជីអត្រានុកូលដ្ឋាន និង ការចុះឈ្មោះអ្នកបោះឆ្នោតតែប៉ុណ្ណោះ ។ ទន្ទឹមនេះ ទោះបីច្បាប់អង្គការបានប្រគល់សិទ្ធិអោយឃុំ សង្កាត់ទទួលបាននូវប្រភពចំណូលផ្ទាល់ខ្លួនក៏ដោយ ក៏កន្លងមកឃុំ សង្កាត់មានចំណូលពីប្រភពតែមួយប៉ុណ្ណោះ គឺ ការផ្ទេរថវិកាពីថ្នាក់ជាតិតាមរយៈមូលនិធិឃុំ សង្កាត់ ។ លើសពីនេះ សមត្ថភាពរបស់ឃុំ សង្កាត់ក៏នៅមានកំរិតទាប កិច្ចប្រតិបត្តិការរវាងអន្តរឃុំ សង្កាត់ ពុំទាន់បានដំណើរការ រចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងនៅថ្នាក់ខេត្ត ក្រុង សំរាប់ផ្តល់ការគាំទ្រ និង ពិនិត្យ នីត្យានុកូលភាពដល់រដ្ឋបាលមូលដ្ឋានក៏ពុំទាន់បានពង្រឹង ។

សរុបមក រហូតមកដល់បច្ចុប្បន្ននេះ ទំនាក់ទំនងរវាង បណ្តាក្រសួង និង ស្ថាប័ននៅថ្នាក់ជាតិ និង ថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ មានលក្ខណៈមិនច្បាស់លាស់ រវាងប្រព័ន្ធប្រមូលផ្តុំ ប្រព័ន្ធវិសហមជ្ឈការ និង ប្រព័ន្ធវិមជ្ឈការ ។ ប៉ុន្តែប្រព័ន្ធដឹកនាំមុខខ្លាំងក្លាជាងគេនាពេលបច្ចុប្បន្ននេះគឺជាប្រព័ន្ធប្រមូលផ្តុំគ្រប់គ្រងតាមខ្សែរយៈបណ្តោយ ។ បន្ថែមពីលើនេះ ការត្រួតជាន់ភារកិច្ចគ្នាខ្លះៗ និង ការកំណត់ភារកិច្ចមិនបានច្បាស់បានបង្ក អោយមានការលំបាកជាខ្លាំងក្នុងការសំរបសំរួលការផ្តល់សេវា

សាធារណៈ និង ការអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព និង និរន្តរភាព នៅថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ ។

ក្នុងន័យនេះ ការកែទំរង់ ការគ្រប់គ្រងរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌតាមបែបវិមជ្ឈការ វិសហមជ្ឈការ និង ការបន្តកំណែទំរង់ ថ្នាក់ឃុំ សង្កាត់ គឺជាការចាំបាច់ ។

## II-<u>ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា</u> :

### ១-<u>ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការរៀបចំប្រព័ន្ធគ្រប់គ្រងនៅថ្នាក់រដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់</u> :

រាជរដ្ឋាភិបាល នឹងបង្កើតប្រព័ន្ធគ្រប់គ្រងនៅថ្នាក់រដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ដោយឈរលើ " គោលការណ៍នៃការចូលរួមតាមលក្ខណៈប្រជាធិបតេយ្យ "ហើយត្រូវដំណើរការប្រកបដោយតម្លាភាព និង គណនេយ្យភាព ដើម្បីជំរុញកិច្ចអភិវឌ្ឍន៍មូលដ្ឋាន និង ការផ្តល់សេវាសាធារណៈដើម្បីឆ្លើយតបនឹង តំរូវការរបស់ប្រជាពលរដ្ឋ ព្រមទាំងការចូលរួមកាត់បន្ថយភាពក្រីក្រនៅក្នុងដែនដីរបស់ខ្លួន ។

អនុលោមតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាល នឹងដាក់អោយដំណើរការនូវប្រព័ន្ធគ្រប់គ្រងនៅថ្នាក់រដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ តាមគោលការណ៍ ដូចខាងក្រោម :

-រដ្ឋបាលឯកភាពមួយ នឹងដាក់អោយដំណើការនៅថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ។ រដ្ឋបាលឯកភាពនេះត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល និង ចំពោះប្រជាពលរដ្ឋក្នុងដែនដីរបស់ខ្លួនក្នុងគោលដៅនៃការពង្រឹងអង្គឯកភាពនៃរដ្ឋ ។

- នៅថ្នាក់ឃុំ សង្កាត់ ទោះបីក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាអាជ្ញាធរមូលដ្ឋាន ត្រូវបានបង្កើតរួចហើយ តាមរយៈការបោះឆ្នោតកាលពីខែកុម្ភៈ ឆ្នាំ ២០០២ ក៏ពិតមែន ប៉ុន្តែរាជរដ្ឋាភិបាលចាំបាច់ត្រូវបន្តពង្រឹង និង កែលំអប្រព័ន្ធគ្រប់គ្រងនេះ អោយកាន់តែមានប្រសិទ្ធភាពថែមទៀត ដើម្បីឆ្លើយនឹងតំរូវការនៃការអភិវឌ្ឍន៍ និងការកាត់បន្ថយភាពក្រីក្រ ។

ផ្អែកតាមគោលការណ៍ នៃការកែទំរង់ខាងលើនេះ រដ្ឋបាលឯកភាពនៅថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ ទាំងនេះ នឹងជួយជំរុញកិច្ចសំរបសំរួលនូវរាល់សកម្មភាពរដ្ឋបាលសាធារណៈនៅក្នុងដែនដីរបស់ខ្លួន សំដៅជំរុញកិច្ចអភិវឌ្ឍន៍ និង ការផ្តល់សេវាសាធារណៈ ដើម្បីឆ្លើយតបតាមសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ។

នៅថ្នាក់ឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ នឹងត្រូវបំពេញតួនាទីអោយកាន់តែសំខាន់ឡើង១ ក្នុងដំណើរការរៀបចំផែនការ ថវិកា និង ការអនុវត្តកិច្ចអភិវឌ្ឍន៍មូលដ្ឋាន និង ការផ្តល់សេវាសាធារណៈចាំបាច់ជាមូលដ្ឋានមួយចំនួន ។ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបំពេញមុខងារផ្ទាល់ដែលបានកំណត់នៅក្នុងច្បាប់ និង មុខងារ ដែលបានធ្វើប្រតិភូកម្មអោយ ។

ដើម្បីឆ្លើយតបបានតាមគោលការណ៍នៃការកែទំរង់នេះ ថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ត្រូវទទួលបាននូវសិទ្ធិអំណាច ក្នុងក្របខ័ណ្ឌកំណត់នៃច្បាប់ ។ ទន្ទឹមនេះ ក៏ត្រូវអនុវត្តគោលនយោបាយ និង កម្មវិធីជាតិ ស្របតាមបទបញ្ញត្តិនៃច្បាប់ និង លិខិតបទដ្ឋាននានា ។ ក្នុងក្របខ័ណ្ឌកំណត់នៃច្បាប់ ចំពោះកិច្ចការទាំងឡាយណា ដែលច្បាប់ពុំបានចែងថា ប្រគល់ភារកិច្ចអោយថ្នាក់រដ្ឋបាលណាមួយ ថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ អាចមានលទ្ធភាពក្នុងការធ្វើការសំរេចចិត្ត និង

អនុវត្តគំរោង និង កម្មវិធីដែល ឆ្លើយតបនឹងតំរូវការ និង អាទិភាពរបស់មូលដ្ឋានខ្លួន ។

ដើម្បីគាំទ្រដល់នយោបាយកំណែទំរង់នេះថ្នាក់ជាតិ ត្រូវកំណត់ច្បាស់លាស់នៅក្នុងច្បាប់ និង លិខិតបទដ្ឋាននានាអំពីភារកិច្ចរបស់ ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ដោយផ្អែកលើសមត្ថភាពរបស់ ថ្នាក់នីមួយៗ ក្នុងការផ្តល់សេវាសាធារណៈ ការគ្រប់គ្រងកិច្ចអភិវឌ្ឍន៍ និង ធនធានហិរញ្ញវត្ថុ (រួមមានប្រភព ចំណូលផ្ទាល់ និង ចំណូលដែលបានទទួលពីថ្នាក់ជាតិ) ដើម្បីធានាការគ្រប់គ្រងតាមថ្នាក់រដ្ឋបាលនីមួយៗអោយ មានប្រសិទ្ធភាពខ្ពស់ ។ប៉ុន្តែសកម្មភាពទាំងឡាយណាដែលមានសារៈសំខាន់ជាយុទ្ធសាស្ត្រសំរាប់ប្រទេសជាតិ ត្រូវតែស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ថ្នាក់ជាតិដដែល ។

## ២. គោលការណ៍ជាមូលដ្ឋានសំរាប់កំណែទំរង់វិមជ្ឈការ និង វិសហមជ្ឈការៈ

កំណែទំរង់ប្រព័ន្ធគ្រប់គ្រងនៅថ្នាក់រដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ មានគោលដៅ ជាយុទ្ធសាស្ត្រពីរយ៉ាង គឺ ÷

**មួយ** : ការពង្រឹង និង ពង្រីកលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន

**ពីរ** : ការជំរុញកិច្ចអភិវឌ្ឍន៍មូលដ្ឋាន និង ការកាត់បន្ថយភាពក្រីក្រ ។

ដូច្នេះកំណែទំរង់នេះ ត្រូវរៀបចំឡើងដោយផ្អែកតាមគោលការណ៍សំខាន់ៗដូចខាងក្រោម ÷

- **ភាពជាតំណាងតាមលទ្ធិប្រជាធិបតេយ្យ**: កំណែទំរង់ នឹង ពង្រឹងតួនាទីរបស់ក្រុមប្រឹក្សា តាមថ្នាក់រដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ

សង្កាត់ ដែលបង្កើតឡើងតាម គោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរី ដោយពង្រីកអំណាច ភារកិច្ចទទួលខុសត្រូវ និង ធនធាន ។

- **ការចូលរួមរបស់ប្រជាពលរដ្ឋ** :កំណែទំរង់ នឹងរៀបចំប្រព័ន្ធ និង ទំរង់ការនានាសំរាប់ប្រជាពលរដ្ឋ ពិសេសស្ត្រី និង ក្រុមជនងាយរង គ្រោះ ក្រុមជនជាតិដើមភាគតិច អាចចូលរួមក្នុងការធ្វើសេចក្តីសំរេចចិត្ត នៅតាមបណ្តាថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ។

- **គណនេយ្យភាព នៃវិស័យសាធារណ** : កំណែទំរង់ នឹង ពង្រឹង គណនេយ្យភាពនៅគ្រប់លំដាប់ ថ្នាក់រដ្ឋបាល និង សំរួលការចូលរួមពិនិត្យមើលរបស់ប្រជាពលរដ្ឋក្នុងកិច្ចការរដ្ឋបាល និង ហិរញ្ញវត្ថុ ។

- **ប្រសិទ្ធភាព** : កំណែទំរង់ នឹងនាំសេវាសាធារណៈអោយគៀកជាប់នឹងអ្នកប្រើប្រាស់ ដោយអនុញ្ញាតអោយប្រជាពលរដ្ឋបានចូលរួមក្នុងការរៀបចំផែនការ និង ការត្រួតពិនិត្យសេវាសាធារណៈទាំងនោះ ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និង អាទិភាពរបស់មូលដ្ឋាន ។ ទន្ទឹមនេះ កំណែទំរង់នឹងកែលំអប្រព័ន្ធរដ្ឋបាល និង ការងារសំរបសំរួល និង ពង្រឹងសមត្ថភាពគ្រប់គ្រងរបស់ថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ដើម្បីលើកកំពស់គុណភាពសេវា ព្រមទាំងពង្រីកការងារផ្តល់សេវាសាធារណៈអោយបានទូលំទូលាយ ។

- **ការផ្តោតទៅលើការកាត់បន្ថយភាពក្រីក្រ** :កំណែទំរង់នេះនឹងពង្រឹងសមត្ថភាពរបស់ មូលដ្ឋាន ក្នុងការប្រើប្រាស់ធនធានសំរាប់គាំទ្រដល់សកម្មភាពកាត់បន្ថយភាពក្រីក្រ ពិសេសក្រុមជនងាយរងគ្រោះ ក្រុមជនជាតិដើមភាគតិច ស្ត្រី និង កុមារ ដើម្បីឈានទៅសំរេចគោលដៅអភិវឌ្ឍន៍សហសវត្សរ៍របស់កម្ពុជា ។

### ៣. វិធីសាស្ត្រនៃការអនុវត្តកំណែទម្រង់:

រាជរដ្ឋាភិបាលទទួលស្គាល់ថា ការសំរេចអោយបាននូវចក្ខុវិស័យនៃកំណែទំរង់ប្រព័ន្ធគ្រប់គ្រង នៅថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ទាមទារនូវពេលវេលា មនសិកាជាតិ ការប្តេជ្ញាចិត្តឥតរាថយ ការផ្លាស់ប្តូរឥរិយាបថ និង ទំលាប់ការងារ ព្រមទាំងកិច្ចខិតខំប្រឹងប្រែងឥតសំចៃពីគ្រប់ភាគីពាក់ព័ន្ធ ដើម្បីកសាងប្រព័ន្ធច្បាប់ និង បទបញ្ញត្តិចាំបាច់នានា ព្រមទាំងរៀបចំឡើងវិញនូវ ប្រព័ន្ធគ្រប់គ្រង ដែលមានបច្ចុប្បន្នដើម្បីចាក់គ្រឹះលទ្ធិ ប្រជាធិបតេយ្យ ដែលកំពុងដំណើរការនាពេលបច្ចុប្បន្នអោយបានរឹងមាំបន្ថែមទៀត ។ ដើម្បី ធានាចិរភាពនៃដំណើរការនេះ រាជរដ្ឋាភិបាលនឹងប្រកាន់យក "អភិក្រមអនុវត្តតាមជំហាន១" សំរាប់គ្រប់គ្រងដំណើរការផ្លាស់ប្តូរដ៏សំខាន់ និង ធំធេងនេះ ព្រមទាំងរៀបចំកម្មវិធីជាតិ និង ផែនការសកម្មភាព និង ថវិកា សំរាប់អនុវត្តកំណែទំរង់នេះ ។

## III- យុទ្ធសាស្ត្រវិមជ្ឈការ និង វិសហមជ្ឈការរបស់រាជរដ្ឋាភិបាលកម្ពុជា :

### ១. វិសាលភាពនៃយុទ្ធសាស្ត្រវិមជ្ឈការ និង វិសហមជ្ឈការ :

យុទ្ធសាស្ត្រវិមជ្ឈការ និង វិសហមជ្ឈការ គឺជាសេចក្តីថ្លែងការណ៍ខាងគោលនយោបាយរបស់រាជរដ្ឋាភិបាល សំរាប់អនុវត្តចក្ខុវិស័យ ស្តីពីប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៅតាមថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ។ យុទ្ធសាស្ត្រវិមជ្ឈការ និង វិសហមជ្ឈការ នឹងបញ្ជាក់អំពី ÷

- គោលដៅ និង អាទិភាពនៃយុទ្ធសាស្ត្រវិមជ្ឈការ និង វិសហមជ្ឈការ ។

- ខ្លឹមសារជាមូលដ្ឋាននៃកំណែទំរង់ ដើម្បីសំរេចគោល ដៅ និង អាទិភាពនៃ យុទ្ធសាស្ត្រ វិមជ្ឈការ និងវិសហមជ្ឈការ ។

-ការប្រែប្រួលទាំងឡាយខាងរចនាសម្ព័ន្ធគ្រប់គ្រង ដែលមានបច្ចុប្បន្ន។

**២_ បណ្តាគោលដៅ និង អាទិភាពនៃយុទ្ធសាស្ត្រវិមជ្ឈការ និង វិសហមជ្ឈការ :**

គោលដៅអភិវឌ្ឍន៍រយៈពេលវែង នៃយុទ្ធសាស្ត្រវិមជ្ឈការ និង វិសហមជ្ឈការរបស់រាជរដ្ឋាភិបាល គឺការអភិវឌ្ឍន៍យ៉ាងទូលំទូលាយ និង ប្រកបដោយចិរភាព ការពង្រឹងមូលដ្ឋានគ្រឹះសំរាប់ខឿនសេដ្ឋកិច្ច ប្រកប ដោយភាពស្វាហាប់នៅមូលដ្ឋាន ដែលប្រជាពលរដ្ឋគ្រប់រូបមានកាលានុវត្តភាព ស្មើៗគ្នា ក្នុងការចូលរួមកិច្ចអភិវឌ្ឍន៍មូលដ្ឋាន ការគ្រប់គ្រងបរិស្ថាន និង ធនធានធម្មជាតិ ប្រកបដោយប្រសិទ្ធភាព និង ការផ្តល់សេវាសាធារណៈ ប្រកបដោយគុណភាព ដើម្បីឆ្លើយតបនឹងតម្រូវការ របស់ប្រជាពលរដ្ឋ និង ការចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ដោយផ្តោតជាសំខាន់ទៅ លើក្រុមជនងាយរងគ្រោះ ក្រុមជនជាតិដើម ភាគតិច ស្ត្រី និង កុមារ ។

ការបង្កើត និង ការលើកកំពស់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ នៅថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ នឹង អាចសំរេចបានយ៉ាង ប្រសើរនូវការពង្រឹងអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យនៅកម្ពុជា ។

ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនេះមានការពាក់ព័ន្ធ នឹង កិច្ចការ ៣ យ៉ាងដូចខាង ក្រោម ÷

**មួយ** : ការបង្កើតស្ថាប័ននៅថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ដែលមានតំណាងជាប់ឆ្នោត ដើម្បីជួយលើកកំពស់ ការចូលរួម

របស់ប្រជាពលរដ្ឋ សំដៅលើកកំពស់ការឆ្លើយតបចំពោះតំរូវការនៅមូលដ្ឋាន និងអនុញ្ញាតអោយមូលដ្ឋានធ្វើការសំរេចចិត្តប្រកាន់យកជំរើសនានាទាក់ទងនឹងការអភិវឌ្ឍន៍មូលដ្ឋានដែលមានគណនេយ្យភាពចំពោះសេចក្ដីសំរេច និង សកម្មភាពរបស់ខ្លួន ។

**ពីរ** : ការធានាអោយមានការផ្ដល់សេវា និង ហេដ្ឋារចនាសម្ព័ន្ធ និង ការកាត់បន្ថយភាពក្រីក្រ ។ ប្រការនេះ ទាមទារអោយបង្កើតឡើងនូវស្ថាប័ននៅថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដែលមានរចនាសម្ព័ន្ធ និងប្រព័ន្ធ ព្រមទាំងសមត្ថភាពផ្នែករដ្ឋបាល និង ហិរញ្ញវត្ថុ ដែលអាចធានាចំពោះការផ្ដល់សេវា និង ហេដ្ឋារចនា សម្ព័ន្ធ ។

**បី** : ការធានាអោយសមាសភាគទាំងពីរខាងលើនេះមានទំនាក់ទំនងជាមួយគ្នាជាប្រចាំ ។ ដើម្បី សំរេចបាននូវគោលដៅនេះ ការផ្ដល់សេវា និង ហេដ្ឋារចនាសម្ព័ន្ធ ត្រូវមានការពិគ្រោះយោបល់ជាមួយស្ថាប័ននយោបាយនៅថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ។

ដូច្នេះទិសដៅនៃវិមជ្ឈការ និង វិសហមជ្ឈការ គឺដើម្បីបង្កើត និង លើកកំពស់ការអភិវឌ្ឍន៍តាម បែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោម ជាតិ ។

ដំណើរការកំណែទំរង់នេះ ត្រូវការពេលវេលាយូរ ប្រហែលជារហូតដល់ទសវត្សបន្ទាប់ ។ ហេតុនេះក្នុងការអនុវត្តត្រូវមានភាពទន់ភ្លន់ បត់បែន ដោយផ្អែកទៅលើមេរៀនបទពិសោធន៍ ដែលទទួលបានជាបន្តបន្ទាប់ក្នុងដំណើរការកែទំរង់នេះ ។

គោលដៅចំពោះមុខនៃយុទ្ធសាស្ត្រវិមជ្ឈការ និង វិសហមជ្ឈការរបស់រាជរដ្ឋាភិបាល គឺការ កសាងស្ថាប័នគ្រប់គ្រងនៅថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ដែលមានលក្ខណៈប្រជាធិបតេយ្យ មានការចូលរួម

មានគណនេយ្យភាព និង មានប្រសិទ្ធភាព ។

ក្នុងការអនុវត្តយុទ្ធសាស្ត្រវិមជ្ឈការ និង វិសហមជ្ឈការ និង ក្នុងក្របខ័ណ្ឌនៃគោលដៅ យូរអង្វែង និង ចំពោះមុខរាជរដ្ឋាភិបាល នឹង ផ្តល់អាទិភាពទៅលើកិច្ចការដូចខាងក្រោម ÷

- រៀបចំរចនាសម្ព័ន្ធស្ថាប័នឡើងវិញនៅថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ តាមរយៈការបង្កើតរដ្ឋបាល ឯកភាព និង ការពង្រឹងគណនេយ្យភាព របស់រដ្ឋបាលទាំងនេះ ចំពោះរាជរដ្ឋាភិបាល និង ចំពោះប្រជាពលរដ្ឋ នៅក្នុងដែនដីរបស់ខ្លួន ។

- ពង្រឹងរដ្ឋបាលឃុំ សង្កាត់ តាមរយៈការបង្កើនភារកិច្ចទទួលខុសត្រូវ និង ការបង្កើនធនធានរបស់រដ្ឋបាលឃុំ សង្កាត់សំរាប់ផ្តល់សេវាសាធារណៈ និង ការអភិវឌ្ឍន៍ ព្រមទាំងពង្រឹងសមត្ថភាព របស់រដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ សំរាប់គាំទ្រដល់ឃុំ សង្កាត់ ។

### ៣-ខ្លឹមសារជាមូលដ្ឋានក្នុងការកែទំរង់ :

ការអនុវត្តយុទ្ធសាស្ត្រវិមជ្ឈការ និង វិសហមជ្ឈការតំរូវឱ្យមានកំណែទំរង់យ៉ាងជ្រាលជ្រៅ ទៅលើប្រព័ន្ធគ្រប់គ្រង ដែលមានបច្ចុប្បន្ននៅថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ។ ដើម្បីឆ្លើយតបនឹងគោលដៅចំពោះមុខ និង បណ្តាអាទិភាពរបស់រាជរដ្ឋាភិបាល កំណែទំរង់ត្រូវផ្តោតទៅលើកិច្ចការសំខាន់ៗដូចខាងក្រោម ÷

**ក-** បង្កើតរដ្ឋបាលឯកភាពនៅថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ ហើយផ្តល់សិទ្ធិអំណាចដល់រដ្ឋបាល ទាំងនោះក្នុងការរៀបចំអនុម័ត និងអនុវត្តផែនការអភិវឌ្ឍន៍ និងថវិកា ការគ្រប់គ្រងបុគ្គលិក ព្រមទាំងសំរបសំរួល

ការគ្រប់គ្រងកិច្ចអភិវឌ្ឍន៍ និង ផ្ដល់សេវាសាធារណៈនៅក្នុងដែនដីរបស់ខ្លួន ។

ក្នុងន័យនេះ នៅថ្នាក់រដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបង្កើតឱ្យមានក្រុមប្រឹក្សាមួយ តាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរី ដើម្បីធានាដល់កិច្ចដំណើរការការងាររបស់ថ្នាក់រដ្ឋបាលទាំងនោះ ប្រកបដោយតម្លាភាព និង គណនេយ្យភាព ។ ក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបង្កើតឡើងតាមការបោះឆ្នោតអសកល ។ ក្រុមប្រឹក្សានៅតាមថ្នាក់រដ្ឋបាលទាំងនេះ ត្រូវធានាអោយមានស្ត្រីចូលរួម ។ ក្រុមប្រឹក្សាមានប្រធានមួយរូប ដែលជ្រើសតាំងឡើងពីក្នុងចំណោមសមាជិកក្រុមប្រឹក្សា ។

ទន្ទឹមនេះ នៅថ្នាក់រដ្ឋបាលទាំងនេះ ត្រូវរៀបចំអោយមានគណៈអភិបាលមួយដែលរួមមាន អភិបាល អភិបាលរង និង សមាជិកមួយចំនួនតាមការចាំបាច់ ។ គណៈអភិបាលនេះ មានអភិបាលខេត្ត ក្រុង ស្រុក ខណ្ឌជាប្រធាន ។

**ខ**- ដើម្បីឆ្លើយតបតាមសំណូមពរនៃការកែទំរង់នេះ ត្រូវធ្វើការផ្ទេរភារកិច្ចទទួលខុសត្រូវ ខាងការងាររដ្ឋបាល និង ការគ្រប់គ្រងកិច្ចអភិវឌ្ឍន៍មូលដ្ឋានទៅអោយ រដ្ឋបាលឯកភាពនៅខេត្ត ក្រុង ស្រុក ខណ្ឌ និង អាជ្ញាធរមូលដ្ឋានឃុំ សង្កាត់ ។ ទន្ទឹមនេះ ត្រូវពិនិត្យ និង កែសំរួលទំនាក់ទំនងខាងសារពើពន្ធ រវាងបណ្ដា ថ្នាក់រដ្ឋបាល និង ទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុ ដើម្បីផ្ដល់ធនធានហិរញ្ញវត្ថុ សំដៅរៀបចំប្រព័ន្ធថវិកាឯកភាព មួយនៅថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ។ ព្រមជាមួយនេះ ត្រូវពង្រឹងទំនាក់ទំនងខាងស្ថាប័ន តាមខ្សែរយៈទទឹង និងខ្សែរយៈបណ្ដោយនៅគ្រប់លំដាប់ថ្នាក់រដ្ឋបាល ដើម្បីបែងចែកភារកិច្ច

ទទួលខុសត្រូវ និងផ្ទេរធនធានសំរាប់ការផ្តល់សេវាសាធារណៈ ដោយត្រូវធានាអោយមានសង្គតិភាពជាមួយគោលនយោបាយ របស់ថ្នាក់ជាតិ ។

គ- ដើម្បីផ្តល់ការគាំទ្រយ៉ាងពិតប្រាកដដល់រដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ត្រូវយកចិត្តទុកដាក់ពង្រឹងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ននានា នឹងត្រូវពិនិត្យឡើងវិញនូវតួនាទី ភារកិច្ច រចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួង និង ស្ថាប័នថ្នាក់ជាតិអោយបានសមស្រប ។

## ៤-ការប្រែប្រួលអំពីការគ្រប់គ្រងថ្នាក់រដ្ឋបាលក្រោមជាតិ :

ការអនុវត្តយុទ្ធសាស្ត្រវិមជ្ឈការ និង វិសហមជ្ឈការ តំរូវអោយមានការផ្លាស់ប្តូរយ៉ាងជ្រាលជ្រៅខាងរចនាសម្ព័ន្ធ និង មុខងារនៅគ្រប់លំដាប់ថ្នាក់រដ្ឋបាល ។

ផ្អែកលើមូលដ្ឋាននេះ ប្រព័ន្ធ និង រចនាសម្ព័ន្ធនៅថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌនឹងត្រូវរៀបចំ ដូចខាងក្រោម ÷

### ក-ការគ្រប់គ្រងថ្នាក់រដ្ឋបាលខេត្ត និងក្រុង (រួមមាន ក្រុងព្រះសីហនុ ក្រុងកែប និង ក្រុងប៉ៃលិន) :

- នៅថ្នាក់រដ្ឋបាលខាងលើនេះ ត្រូវបង្កើតនូវរដ្ឋបាលឯកភាពមួយ ដែលមានលក្ខណៈជា នីតិបុគ្គល ។ ភាពជានីតិបុគ្គលនេះត្រូវផ្តល់ដល់ខេត្ត ក្រុងទាំងមូល ដែលរួមមានដែនដី ប្រជាពលរដ្ឋ និង ក្រុមប្រឹក្សារបស់ខ្លួន ។

- ខេត្ត ក្រុងនីមួយៗត្រូវបង្កើតអោយមានក្រុមប្រឹក្សាខេត្ត ក្រុង តាមការបោះឆ្នោតអសកល ដោយអនុលោមតាមបទបញ្ញត្តិនៃច្បាប់

អង្គការ ។ ចំនួនអាសនៈនៃក្រុមប្រឹក្សាខេត្ត ក្រុង នឹងកំណត់ដោយផ្អែកតាមកត្តាភូមិសាស្ត្រ និង ប្រជាសាស្ត្រ ។ ក្រុមប្រឹក្សាខេត្ត ក្រុង មានអាណត្តិ ៥ ឆ្នាំ ។

- ខេត្ត ក្រុងនីមួយៗ ត្រូវរៀបចំអោយមានអភិបាលខេត្ត ក្រុងមួយរូប ដែលតែងតាំងដោយព្រះរាជក្រឹត្យ ។ អភិបាលខេត្ត ក្រុងមានអភិបាលរងមួយចំនួនជាជំនួយការ ដែលតែងតាំងឡើងដោយរាជរដ្ឋាភិបាល ។

- ខេត្ត ក្រុងនីមួយៗ ត្រូវរៀបចំអោយមាន គណៈអភិបាលខេត្ត ក្រុង ដែលមានអភិបាល អភិបាលរងខេត្ត ក្រុង និង សមាជិកមួយចំនួនតាមការចាំបាច់ ។ គណៈអភិបាលខេត្ត ក្រុង មានអភិបាលខេត្តក្រុងជាប្រធាន ។ គណៈអភិបាលខេត្ត ក្រុង ត្រូវទទួលខុសត្រូវក្នុងការចាត់ចែងការងារនៅក្នុងខេត្ត ក្រុង របស់ខ្លួន ។

- ក្រុមប្រឹក្សាខេត្ត ក្រុង ជាអង្គការតំណាងប្រជាពលរដ្ឋក្នុងខេត្តក្រុង មានភារកិច្ចធ្វើការ ពិភាក្សា និង ផ្តល់ការយល់ព្រមលើផែនការនិង ថវិកាខេត្ត ក្រុង ព្រមទាំងពិនិត្យ និង វាយតំលៃបណ្តាសកម្មភាពរបស់អភិបាលខេត្ត ក្រុង គណៈអភិបាលខេត្ត ក្រុង និង រដ្ឋបាលឯកភាពខេត្ត ក្រុង ។ ក្នុងករណី ចាំបាច់អាចតំរូវអោយអភិបាលខេត្ត ក្រុងធ្វើការបំភ្លឺបញ្ហានានាដែលពាក់ព័ន្ធនឹងសេចក្តីសំរេចរបស់ខ្លួន ។ ក្រុមប្រឹក្សាមានសិទ្ធិអង្កេតលើករណីទាំងឡាយណាដែលខ្លួនយល់ឃើញថា មានសារៈសំខាន់ដល់ប្រជាពលរដ្ឋ ដែលខ្លួនជាតំណាង ព្រមទាំងអាចផ្សព្វផ្សាយលទ្ធផលនៃការធ្វើអង្កេតនោះ និង ផ្តល់អនុសាសន៍ដល់គណៈអភិបាល ខេត្តក្រុង និង អភិបាលខេត្ត ក្រុង ។

- អភិបាលខេត្ត ក្រុងជាអ្នកចាត់ចែងការងារប្រចាំថ្ងៃរបស់ ខេត្ត

ក្រុង ។ អភិបាលខេត្ត ក្រុងជាតំណាងរបស់រាជរដ្ឋាភិបាល និងរដ្ឋមន្ត្រីនៃក្រសួង និង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល និង រដ្ឋបាល ខេត្ត ក្រុងរបស់ខ្លួន ។

- អភិបាលខេត្ត ក្រុងមានភារកិច្ចសំខាន់ៗ ដូចជាការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និង បណ្តាភារកិច្ចផ្សេងៗទៀតជំនួសមុខអោយថ្នាក់ជាតិ ព្រមទាំងការគ្រប់គ្រងកម្មវិធីអភិវឌ្ឍន៍ និង ការផ្តល់សេវាសាធារណៈក្នុងខេត្ត ក្រុងរបស់ខ្លួន ។ អភិបាលខេត្ត ក្រុង ត្រូវមានគណនេយ្យភាពក្នុងរាល់កិច្ចការរបស់ រដ្ឋបាលឯកភាពខេត្ត ក្រុង ចំពោះរាជរដ្ឋាភិបាល គណៈអភិបាលខេត្ត ក្រុង និង ក្រុមប្រឹក្សាខេត្ត ក្រុងរបស់ខ្លួន ។

- រដ្ឋបាលខេត្ត ក្រុងមានអគ្គលេខាធិការដ្ឋានមួយ និង ខុទ្ទកាល័យមួយ សំរាប់ជួយរាល់ការងារ របស់រដ្ឋបាលឯកភាពខេត្ត ក្រុង ។

- រដ្ឋបាលឯកភាព ខេត្ត ក្រុងមានភារកិច្ច គ្រប់គ្រងសកម្មភាពអភិវឌ្ឍន៍ និងផ្តល់សេវាសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធ ស្របតាមបទបញ្ញត្តិនៃច្បាប់អង្គការ និង គោលនយោបាយទូទៅរបស់ជាតិ ។

- ខេត្ត ក្រុង ត្រូវមានថវិកាឯកភាព និង មានប្រព័ន្ធគ្រប់គ្រងបុគ្គលិករបស់ខ្លួននៅថ្នាក់ខេត្ត ក្រុង ។ ខេត្តក្រុងមានសិទ្ធិទទួលថវិកាមួយចំណែក ឬ ថវិកាទាំងស្រុង ដែលប្រមូលបាននៅក្នុងខេត្ត ក្រុង និងអាចទទួលថវិកាផ្ទេរមកពីថ្នាក់ជាតិ ( សំរាប់ចំណាយទូទៅ និងចំណាយជាក់លាក់តាមវិស័យ ) ។ ទំហំថវិកា ទាំងនេះត្រូវសមល្មមនឹងទំហំភារកិច្ចទទួលខុសត្រូវរបស់ខេត្ត ក្រុងក្នុងការផ្តល់សេវា ។

- អភិបាលខេត្ត ក្រុងមានភារកិច្ចត្រួតពិនិត្យអំពីនីត្យានុកូលភាព

ការងាររបស់ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ជំនួសមុខអោយថ្នាក់ជាតិ ។

ខ-ការគ្រប់គ្រងរដ្ឋបាលក្រុងភ្នំពេញ :

ចំពោះក្រុងភ្នំពេញដែលជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបង្កើតនូវរដ្ឋបាលឯកភាព មួយដែលមានលក្ខណៈជានីតិបុគ្គល ។

ការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង អភិបាល អភិបាលរង ក្រុង អគ្គលេខាធិការដ្ឋាន និង ខុទ្ទកាល័យក្រុងភ្នំពេញមានលក្ខណៈដូចខេត្ត ក្រុងដទៃទៀតដែរ ។

ក្រុងភ្នំពេញត្រូវចែកជាខណ្ឌ ។ ខណ្ឌត្រូវចែកជាសង្កាត់ ។ ខណ្ឌ និង សង្កាត់ គឺជាផ្នែកមួយនៃ រដ្ឋបាលឯកភាពក្រុងភ្នំពេញ ។

ដើម្បីលើកកំពស់លទ្ធិប្រជាធិបតេយ្យ និង ការចូលរួម ខណ្ឌនីមួយៗចំណុះក្រុងភ្នំពេញត្រូវរៀបចំ អោយមានក្រុមប្រឹក្សាមួយ ដែលកើតចេញពីការបោះឆ្នោតអសកល ។ ក្រុមប្រឹក្សាខណ្ឌមានអាណត្តិ ៥ ឆ្នាំ ។

ខណ្ឌនីមួយៗ ត្រូវរៀបចំអោយមានអភិបាលខណ្ឌ ដែលតែងតាំងឡើងដោយរាជរដ្ឋាភិបាល ។ អភិបាលខណ្ឌ មានអភិបាលរង ខណ្ឌមួយចំនួនជាជំនួយការ ។

សង្កាត់នីមួយៗ ត្រូវរៀបចំអោយមានក្រុមប្រឹក្សាសង្កាត់ ដែលត្រូវបោះឆ្នោតជ្រើសរើសឡើង តាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

ខណ្ឌ និង សង្កាត់អនុវត្តមុខងារទាំងឡាយក្នុងនាមរដ្ឋបាលឯកភាពក្រុងភ្នំពេញ ស្របទៅតាមបទបញ្ញត្តិនៃច្បាប់អង្គការស្តីពីការគ្រប់គ្រងក្រុងភ្នំពេញ ។

ក្រុងភ្នំពេញត្រូវមានថវិកា ប្រព័ន្ធគ្រប់គ្រងបុគ្គលិកប្រហាក់ប្រហែល នឹងខេត្ត ក្រុងដទៃទៀតដែរ ។ ក្រុងភ្នំពេញមានសិទ្ធិទទួលបានថវិកាមួយចំណែក ឬ ថវិកាទាំងស្រុង ដែលប្រមូលបាននៅក្នុងក្រុង និង អាចទទួលថវិកាផ្ទេរមកពីថ្នាក់ជាតិ ។ ទំហំថវិកាទាំងនេះ ត្រូវសមល្មម នឹងទំហំភារកិច្ចទទួលខុសត្រូវរបស់ក្រុងភ្នំពេញក្នុងការផ្តល់សេវា ។

គ-<u>ការគ្រប់គ្រងថ្នាក់រដ្ឋបាលស្រុក ខណ្ឌ (សំរាប់ស្រុក ខណ្ឌ នៅជនបទ)</u>:

- នៅថ្នាក់ស្រុក ខណ្ឌត្រូវបង្កើតនូវរដ្ឋបាលឯកភាពមួយដែលមានលក្ខណៈប្រហាក់ប្រហែល នឹងថ្នាក់ខេត្ត ក្រុងដែរ ។

- ស្រុក ខណ្ឌនីមួយៗ ត្រូវបង្កើតអោយមានក្រុមប្រឹក្សាស្រុក ខណ្ឌតាមរយៈការបោះឆ្នោត អសកល ស្របតាមបទបញ្ញត្តិ ដែលមានចែងក្នុងច្បាប់អង្គការ ។ ចំនួនអាសនៈនៃក្រុមប្រឹក្សាស្រុក ខណ្ឌ នឹង កំណត់ដោយផ្អែកតាមភូមិសាស្ត្រ និង ប្រជាសាស្ត្រ ។ ក្រុមប្រឹក្សាស្រុក ខណ្ឌមានអាណត្តិ ៥ ឆ្នាំ ។

- ស្រុក ខណ្ឌនីមួយៗ ត្រូវរៀបចំអោយមានអភិបាលស្រុក ខណ្ឌមួយរូប ដែលតែងតាំងដោយ រាជរដ្ឋាភិបាល ។ អភិបាលស្រុក ខណ្ឌមានអភិបាលរងស្រុក ខណ្ឌមួយចំនួនជាជំនួយការ ។ ស្រុក ខណ្ឌ នីមួយៗត្រូវរៀបចំអោយមាន គណៈអភិបាលស្រុក ខណ្ឌ ដែលមានអភិបាល អភិបាលរងស្រុក ខណ្ឌ និង សមាជិកមួយចំនួនទៀតតាមការចាំបាច់ ។ គណៈអភិបាលស្រុក ខណ្ឌមាន អភិបាលស្រុក ខណ្ឌជាប្រធាន ។ គណៈអភិបាល ស្រុក ខណ្ឌត្រូវទទួលខុសត្រូវក្នុងការចាត់ចែងការងារក្នុងស្រុក ខណ្ឌរបស់ខ្លួន ។

- អភិបាលស្រុក ខណ្ឌជាអ្នកចាត់ចែងការងារប្រចាំថ្ងៃ ត្រូវទទួលខុសត្រូវក្នុងការរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និង ការគ្រប់គ្រងកិច្ចអភិវឌ្ឍន៍របស់ស្រុក ខណ្ឌ ។ អភិបាលស្រុក ខណ្ឌ ត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល គណៈអភិបាលស្រុក ខណ្ឌ និង រដ្ឋបាលស្រុក ខណ្ឌរបស់ខ្លួន ។

- រដ្ឋបាលឯកភាពថ្នាក់ស្រុក ខណ្ឌ នឹងត្រូវទទួលមុខងារជាក់លាក់មួយចំនួនក្នុងការផ្តល់សេវាកម្ម និងការគ្រប់គ្រងកិច្ចអភិវឌ្ឍន៍ ។

- ក្នុងដំណាក់កាលដំបូងនៃការកែទំរង់នេះ រដ្ឋបាលឯកភាពនៅថ្នាក់ស្រុក ខណ្ឌមិនទាន់ត្រូវ ចាត់ទុកជាថ្នាក់ថវិកាឡើយ ។ ថវិកា និង ការគ្រប់គ្រងបុគ្គលិករបស់ស្រុក ខណ្ឌ គឺជាផ្នែកមួយនៃថវិកា និង ប្រព័ន្ធគ្រប់គ្រង បុគ្គលិករបស់ខេត្ត ក្រុង ។

**ឃ-<u>ការគ្រប់គ្រងរដ្ឋបាលតំបន់ប្រជុំជន</u> :**

- ចំពោះតំបន់ប្រជុំជន ដូចជាស្រុក ខណ្ឌទីរួមខេត្ត មួយចំនួន និង ឃុំ សង្កាត់ទីប្រជុំជនធំៗមួយចំនួន ត្រូវរៀបចំប្រព័ន្ធគ្រប់គ្រងដូចខាង ក្រោម÷

+ស្រុក ខណ្ឌទីរួមខេត្ត ក្រុង និង ស្រុក ខណ្ឌ ទីប្រជុំជនធំៗ ត្រូវរៀបចំបង្កើតនូវរដ្ឋបាលឯកភាពមួយប្រហាក់ប្រហែលនឹងស្រុក ខណ្ឌ ដទៃទៀតដែរ ប៉ុន្តែមានលក្ខណៈជានីតិបុគ្គល ។

+ ឃុំ សង្កាត់ ទីប្រជុំជន ដែលស្ថិតនៅក្រៅពីរាជធានីភ្នំពេញ និង ក្រៅទីរួមខេត្ត ក្រុង ត្រូវធ្វើការពង្រឹងប្រព័ន្ធគ្រប់គ្រង ឃុំ សង្កាត់ បច្ចុប្បន្ន ដោយរៀបចំបង្កើត បន្ថែមនូវរចនាសម្ព័ន្ធបុគ្គលិកព្រមទាំងពង្រឹងសមត្ថភាព និង ផ្តល់ធនធានបន្ថែមសំដៅឱ្យឃុំ សង្កាត់ទាំងនោះ

ទទួលយកមុខងារថ្មីៗជាបន្ថែមទៀតក្នុងការគ្រប់គ្រង និង ចាត់ចែងទីប្រជុំជន ។

ដើម្បីលើកកំពស់សមត្ថភាពក្នុងការអភិវឌ្ឍន៍ទីប្រជុំជនឃុំ សង្កាត់ ទីប្រជុំជនមួយចំនួន ដែល មានព្រំប្រទល់ជាប់ៗគ្នា ត្រូវធ្វើការពិនិត្យឡើងវិញនូវព្រំប្រទល់របស់ឃុំ សង្កាត់ទាំងនោះដើម្បីធ្វើការកែសំរួល ឱ្យបានសមស្រប ។

ង-<u>ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់</u> :

- នៅថ្នាក់ឃុំ សង្កាត់ អាជ្ញាធរមូលដ្ឋានត្រូវបានបង្កើតឡើងរួចហើយ តាមរយៈការបោះឆ្នោតនៅមូលដ្ឋាន កាលពីខែកុម្ភៈ ឆ្នាំ ២០០២ ។

ដូចនេះ ការអនុវត្តយុទ្ធសាស្ត្រវិមជ្ឈការ វិសហមជ្ឈការនឹង ពង្រឹងធ្វើអោយកាន់តែស៊ីជំរៅថែមទៀតនូវដំណើរការវិមជ្ឈការនៅឃុំ សង្កាត់ ។

- ដើម្បីធានាអោយឃុំ សង្កាត់អនុវត្តបានពេញលេញនូវមុខងារផ្ទាល់ និង មុខងារជាភ្នាក់ងារ ស្របតាមច្បាប់ ភារកិច្ចក្នុងការផ្តល់សេវាសាធារណៈ នឹងត្រូវផ្ទេរអោយបានកាន់តែច្រើនឡើងៗ ទៅអោយឃុំ សង្កាត់។ អភិក្រមនៃការផ្ទេរ ឬការធ្វើប្រតិភូកម្មភារកិច្ចទទួលខុសត្រូវ គឺត្រូវអនុវត្តជាជំហានៗ ដោយធ្វើ ការវាយតំលៃ និង រៀបចំចំណាត់ថ្នាក់ សមត្ថភាពរបស់ឃុំ សង្កាត់ទាំងអស់ ហើយអាចចាប់ផ្តើមផ្ទេរ ឬធ្វើប្រតិភូកម្មភារកិច្ចទទួលខុសត្រូវថ្មីៗបន្ថែមទៀត ក្នុងការផ្តល់សេវាសាធារណៈអោយដល់ឃុំ សង្កាត់ណាដែល មានសមត្ថភាពមុខគេ ។

- យោងតាមខ្លឹមសារខាងលើនេះ ត្រូវរៀបចំច្បាប់ និង បទបញ្ញត្តិដែលពាក់ព័ន្ធនឹងការផ្ទេរ ឬ ការធ្វើប្រតិភូកម្មភារកិច្ចទទួលខុសត្រូវនេះ

រួមទាំងបែបបទក្នុងការផ្ទេរថវិកាពីមន្ទីរជំនាញតាមខេត្ត ក្រុង ស្រុក ខណ្ឌ ទៅអោយឃុំ សង្កាត់ផងដែរ ។

- ធនធានហិរញ្ញវត្ថុរបស់ថ្នាក់ឃុំ សង្កាត់ ត្រូវរៀបចំ ដោយផ្អែកលើទំហំនៃការទទួលខុសត្រូវរបស់ឃុំ សង្កាត់ ។ ធនធានទាំងនេះរួមមាន÷ ការបង្កើនមូលនិធិឃុំ សង្កាត់ ដោយបង្កើនបន្ថែមនូវប្រភពផ្ទេរពីថវិកា ជាតិ ការបង្កើតប្រភពចំណូលផ្ទាល់របស់ឃុំ សង្កាត់ និង ការរំលែកចំណូលមួយចំណែកដែល ឃុំ សង្កាត់បានជួយប្រមូល ។

## ៥-ការកំណត់ បែងចែកភារកិច្ច និងការទទួលខុសត្រូវរវាងបណ្តា ថ្នាក់រដ្ឋបាល :

ការបែងចែកភារកិច្ច និង ការទទួលខុសត្រូវរវាងថ្នាក់ជាតិ និង រដ្ឋបាលថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និង រវាងថ្នាក់រដ្ឋបាលទាំងនេះ ជាមួយនឹងអាជ្ញាធរមូលដ្ឋាន ត្រូវផ្អែកតាមគោលការណ៍ " ប្រសិទ្ធភាព ខ្ពស់បំផុត នៃការផ្តល់សេវាសាធារណៈរបស់ថ្នាក់រដ្ឋបាល ដែលនៅជិតគៀកជាងគេជាមួយប្រជាពលរដ្ឋ និង ការធានាគណនេយ្យភាពចំពោះប្រជាពលរដ្ឋ " ។

ទន្ទឹមនេះ ភារកិច្ចទទួលខុសត្រូវរបស់ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នឹងត្រូវកំណត់អោយបានច្បាស់លាស់ ដែលក្នុងនោះថ្នាក់នីមួយៗ ត្រូវទទួលភារកិច្ចជាក់លាក់មួយចំនួនហើយក៏ទទួលខុសត្រូវចំពោះលទ្ធផល នៃការបំពេញភារកិច្ចរបស់ខ្លួនផងដែរ ។ ច្បាប់អង្គការនឹងកំណត់អំពី បណ្តាភារកិច្ចទទួលខុសត្រូវនៅ តាមវិស័យនីមួយៗរបស់ថ្នាក់រដ្ឋបាល ខេត្ត ក្រុង ស្រុក ខណ្ឌ និង អាជ្ញាធរមូលដ្ឋាន ។ ទោះជា យ៉ាងនេះក៏ដោយ ក៏ អាជ្ញាធរមូលដ្ឋាន ដែលបង្កើតឡើងតាមរយៈការបោះឆ្នោត មានសិទ្ធិ ក្នុង

ការផ្តួចផ្តើមគំនិតទាំងឡាយ សំរាប់ជាគុណប្រយោជន៍របស់ប្រជាពលរដ្ឋ ក្នុងមណ្ឌលរបស់ខ្លួនហើយដែលមិនមែនជាភារកិច្ចផ្ទាល់របស់ថ្នាក់ រដ្ឋបាលណាមួយ ។

## ៦_ការកំណត់ចំណូល និងថវិកានៅតាមបណ្តាថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ :

- ការបែងចែកប្រភពចំណូលរវាងបណ្តាថ្នាក់រដ្ឋបាល ត្រូវតែស្របនឹងទំហំភារកិច្ចទទួលខុសត្រូវ របស់ថ្នាក់រដ្ឋបាលនីមួយៗ ។ ការផ្ទេរភារកិច្ចទទួលខុសត្រូវពីថ្នាក់រដ្ឋបាលមួយទៅថ្នាក់រដ្ឋបាលមួយទៀត ត្រូវដើរទន្ទឹមនឹងការបំពេញថវិកាបន្ថែម ។

- ថ្នាក់រដ្ឋបាលនីមួយៗ ត្រូវមានប្រភពចំណូលរបស់ខ្លួន ដែលរួមមាន ÷ ប្រភពចំណូលថវិកាផ្ទាល់ ប្រភពចំណូលដែលបែងចែកអោយថ្នាក់រដ្ឋបាលនីមួយៗ និង ប្រភពចំណូលថវិកាដែលផ្ទេរពីថ្នាក់លើ ។ កំណែទំរង់ក្នុងវិស័យនេះ ត្រូវផ្តោតការយកចិត្តទុកដាក់ទៅលើបញ្ហាគណនេយ្យភាពចំពោះមូលដ្ឋាន និង ការបង្កើតទំនាក់ទំនងប្រកបដោយតម្លាភាព រវាងទំហំនៃការផ្តល់សេវាសាធារណៈ និង ការប្រមូលចំណូល ។ ម្យ៉ាងវិញទៀត ក៏ត្រូវកំណត់អោយបានច្បាស់លាស់អំពីសិទ្ធិ និង អំណាចក្នុងការប្រមូលចំណូលនៅតាមថ្នាក់ រដ្ឋបាលនីមួយៗ ដើម្បីជៀសវាងភាពមិនច្បាស់លាស់ និង ការត្រួតភារកិច្ចគ្នា ។

- ប្រភេទពន្ធរបស់រដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ និង អាជ្ញាធរមូលដ្ឋានត្រូវតែកំណត់ដោយច្បាប់ ។ បញ្ជីប្រភេទពន្ធនេះ គឺជាបញ្ជីច្បាស់លាស់ ។ ច្បាប់នឹងកំណត់ពីបញ្ជីប្រភេទពន្ធ និង កំណត់ អត្រាប្រមូល

ពន្ធទូទាំងប្រទេស និង អត្រាបែងចែករវាងបណ្តាថ្នាក់រដ្ឋបាល ។

- រដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ និង អាជ្ញាធរមូលដ្ឋានមានសិទ្ធិទទួលចំណូលដែលបានមកពី ការផ្តល់សេវារបស់ខ្លួន ។ ចំណូលទាំងនេះនឹងត្រូវប្រមូលដោយថ្នាក់ដែលបានផ្តល់ សេវាទាំងនោះ ។ ក្នុងក្របខ័ណ្ឌនៃគោលនយោបាយជាតិរដ្ឋបាលខេត្ត ក្រុង និង អាជ្ញាធរមូលដ្ឋានអាចកំណត់អំពីរបៀប ឬ វិធីនៃការប្រមូលចំណូលទាំងនោះប្រកបដោយតម្លាភាព និង ប្រសិទ្ធភាពព្រមទាំងគ្រប់គ្រងប្រភពចំណូលប្រភេទនេះ ។

- ការផ្ទេរថវិកាអោយរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ និង អាជ្ញាធរមូលដ្ឋានត្រូវផ្អែកតាមរូបមន្តមួយដែលមានភាពជាក់លាក់ និងមានតម្លាភាព ។ ការផ្ទេរថវិការួមមានការផ្តល់ថវិកាប្រកបដោយសមភាព សំរាប់ចំណាយចាំបាច់របស់ថ្នាក់រដ្ឋបាលនីមួយៗ ការបំពេញថវិកាបន្ថែមសំរាប់អនុវត្តភារកិច្ចជាក់លាក់ និង ការផ្តល់ការលើកទឹកចិត្តដល់កិច្ចប្រឹងប្រែងប្រមូលចំណូល និង ដល់ការកែលំអការគ្រប់គ្រងចំណាយ ។

- កំណែទំរង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ និង ទំរង់ការនានា មានគោលដៅពង្រឹងបន្ថែមទៀតនូវដំណើរការនៃការរៀបចំផែនការ កម្មវិធីនីយកម្ម ការរៀបចំថវិកា ការអនុវត្ត ការងារលទ្ធកម្ម ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ការងារគណនេយ្យ និង ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ការវាយតំលៃ និង ការធ្វើសវនកម្មទាំងផ្ទៃក្នុង និង ពីខាងក្រៅ ។ ទន្ទឹមនេះក៏គួររៀបចំប្រព័ន្ធសំរាប់លើកទឹកចិត្ត និង ដាក់ពិន័យតាមរយៈ ការផ្ទេរថវិកា ដើម្បីធានាអោយរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ និង អាជ្ញាធរមូលដ្ឋានអនុវត្តបានត្រឹមត្រូវ និង ច្បាស់លាស់តាមទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុព្រមទាំងមានការទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន ។ កំណែទំរង់

នេះ ក៏មានទិសដៅបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុ និង ពង្រឹងប្រព័ន្ធគណនេយ្យភាព ទាំងតាមខ្សែរយៈបណ្តោយទ្វេរទិស និង តាមខ្សែរយៈទទឹងផងដែរ ។ លើសពីនេះ ក៏ត្រូវរៀបចំ និង អនុវត្ត កម្មវិធីពង្រឹងសមត្ថភាពរបស់រដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ និង អាជ្ញាធរមូលដ្ឋាន ដើម្បីគាំទ្រដល់ដំណើរការនៃការប្រែប្រួលនេះ និង ដើម្បីធានាដល់កិច្ច ប្រតិបត្តិការរបស់រដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ និង អាជ្ញាធរមូលដ្ឋាន ប្រកបដោយប្រសិទ្ធភាព ។

## IV- កម្មវិធីជាតិសំរាប់អនុវត្តយុទ្ធសាស្ត្រវិមជ្ឈការ និង វិសហមជ្ឈការ :

### ១-សមាសភាគ និងលទ្ធផលរំពឹងទុកនៃកម្មវិធីជាតិ :

ដើម្បីសំរេចឱ្យបាននូវគោលដៅដូចមានចែងនៅក្នុងយុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការ ទាមទារត្រូវមានការខិតខំប្រឹងប្រែងរយៈពេលយូរអង្វែង ។ ដូចនេះ គួររៀបចំកម្មវិធីជាតិរយៈពេល ៥ ឆ្នាំ សំរាប់អនុវត្តយុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការនេះ ។គោលដៅនៃកម្មវិធីជាតិ គឺការសំរេចឱ្យបាននូវលទ្ធផលរំពឹងទុកសំខាន់៣យ៉ាងដូចតទៅ ÷

**មួយ** : លទ្ធផលរំពឹងទុកខាងផ្នែកគោលនយោបាយ និងបទបញ្ញត្តិ

**ពីរ** : លទ្ធផលរំពឹងទុកខាងផ្នែកស្ថាប័ន និង

**បី** : លទ្ធផលរំពឹងទុកតាមវិស័យ ។

#### ក/-លទ្ធផលរំពឹងទុកខាងផ្នែកគោលនយោបាយ និងបទបញ្ញត្តិ

រួមមាន ÷ច្បាប់អង្គការ និង បទបញ្ញត្តិ នានាសំរាប់អនុវត្តច្បាប់អង្គការ ។

បទបញ្ញត្តិទាំងនេះ រួមបញ្ចូលផងដែរនូវបទបញ្ញត្តិនានា សំរាប់អនុវត្ត កំណែទំរង់ ហិរញ្ញវត្ថុតាមបែបវិមជ្ឈការ និង វិសហមជ្ឈការ និង ការបែងចែកប្រភេទចំណូល និង ចំណាយសំរាប់ថ្នាក់រដ្ឋបាល ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ។ ទន្ទឹមនេះ ក៏ត្រូវរៀបចំគោលនយោបាយតាមវិស័យស្តីពីការបែងចែកភារកិច្ចទទួលខុសត្រូវក្នុងការផ្តល់សេវា សាធារណៈ ដែលថ្នាក់ជាតិត្រូវផ្ទេរ ឬធ្វើ ប្រតិភូកម្មទៅអោយថ្នាក់រដ្ឋបាលនីមួយៗ ។ លើសពីនេះ ក៏ត្រូវរៀបចំបញ្ចប់ក្របខ័ណ្ឌគតិយុត្តិសំរាប់អាជ្ញាធរមូលដ្ឋាន ឃុំ សង្កាត់ធ្វើការប្រមូលចំណូលផ្ទាល់របស់ខ្លួន ព្រមទាំងកែសំរួល បទបញ្ញត្តិទាំងឡាយ ដែលមានជាធរមានអោយមានសង្គតិភាពជាមួយ នឹងប្រព័ន្ធគ្រប់គ្រងដែលមានចែងក្នុងច្បាប់អង្គការ ។

ខ/-**<u>លទ្ធផលរំពឹងទុកខាងផ្នែកស្ថាប័ន</u>** រួមមាន ÷ ការពិនិត្យ និង កែសំរួលឡើងវិញនូវប្រព័ន្ធ គ្រប់គ្រងនៅថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និង ពង្រឹងប្រព័ន្ធគ្រប់គ្រងឃុំ សង្កាត់ ដែលរួមមាន ការបង្កើតរដ្ឋបាល ឯកភាពនៅថ្នាក់ ខេត្ត ក្រុង និង ស្រុក ខណ្ឌ និង ការពិនិត្យឡើងវិញអំពីតួនាទី និង ភារកិច្ចរបស់បណ្តាក្រសួង និង ស្ថាប័ននៅថ្នាក់ជាតិ ។ ទន្ទឹមនេះក៏ត្រូវរៀបចំលិខិតបទដ្ឋានសំរាប់ពង្រឹងស្ថាប័ន សំដៅកែលំអការប្រមូលធនធានអោយមានប្រសិទ្ធភាព ដូចជាការវាយតំលៃប្រភពចំណូល ការប្រមូលចំណូល និង ការបែងចែក ចំណូល ។ល។ និង ការគ្រប់គ្រងចំណាយ ដូចជាសមត្ថភាពក្នុងការរៀបចំផែនការយុទ្ធសាស្ត្រសំរាប់ថ្នាក់រដ្ឋបាលខ្លួន ការរៀបចំកម្មវិធីវិនិយោគ ការរៀបចំថវិកាប្រចាំឆ្នាំ និង ច្រើនឆ្នាំ ការអនុវត្តផែនការ និង គំរោងការគ្រប់គ្រងទ្រព្យសម្បត្តិ ការធ្វើរបាយការណ៍

ហិរញ្ញវត្ថុ និង គណនេយ្យ ការតាមដាន ត្រួតពិនិត្យផ្ទៃក្នុង ។ល។ ទន្ទឹម នេះ ក៏ត្រូវរៀបចំប្រព័ន្ធ និង ទំរង់ការនៃការផ្ទេរ ឬ ការធ្វើប្រតិភូកម្ម ក្នុងការផ្តល់សេវាសាធារណៈ ព្រមទាំងជំរុញកិច្ចសហប្រតិបត្តិការ និង កិច្ចសំរបសំរួលរវាងស្ថាប័ននៅថ្នាក់ជាតិ ជាមួយនឹងរដ្ឋបាល ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ។ ព្រមជាមួយនោះលទ្ធផលសំខាន់ខាង ផ្នែកស្ថាប័ន គឺការអនុវត្តភារកិច្ច របស់រដ្ឋ ក្នុងការផ្តល់ការគាំទ្រ និង ការត្រួតពិនិត្យគ្រប់សកម្មភាពរបស់ថ្នាក់រដ្ឋបាលទាំងនេះ ។ ទន្ទឹមនេះដែរ ក៏ត្រូវរៀបចំយន្តការ និង នីតិវិធីដើម្បីអោយក្រសួងមហាផ្ទៃ និង ក្រសួង ស្ថាប័ននានាធ្វើការពិនិត្យ នីត្យានុកូលភាព និងគុណភាពនៃការបំពេញ ភារកិច្ចរបស់បណ្តាថ្នាក់រដ្ឋបាល ។

គ/. **<u>លទ្ធផលរំពឹងទុកតាមវិស័យ</u>** គឺជាលទ្ធផលដែលរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់បានផ្តល់ នូវសេវា ផ្នែកហេដ្ឋារចនា សម្ព័ន្ធសេដ្ឋកិច្ច និងសង្គមកិច្ច ក៏ដូចជាសេវាសាធារណៈផ្សេងៗ ទៀត ព្រម ទាំងការវិនិយោគសំរាប់គ្រប់គ្រងធនធានធម្មជាតិ និង កិច្ចអភិវឌ្ឍន៍ សេដ្ឋកិច្ចសង្គមនៅមូលដ្ឋាន ។ការសំរេចអោយបាននូវលទ្ធផលនេះ ទាម ទារធនធានយ៉ាងច្រើនពីថវិការដ្ឋ និង ពីសហគមន៍អន្តរជាតិ សំរាប់ គាំទ្រថ្នាក់រដ្ឋបាលនីមួយៗ ក្នុងការរៀបចំ និង អនុវត្តផែនការ និង ថវិកា ព្រមទាំងសំរាប់គាំទ្រដល់មុខងារទាំងឡាយដែលថ្នាក់ជាតិបានរៀបចំ ហើយ បានផ្ទេរ ឬធ្វើប្រតិភូកម្មទៅអោយរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ជាអ្នកអនុវត្ត ។

ផ្អែកតាមលទ្ធផលរំពឹងទុកខាងលើនេះ ក្នុងរយៈពេល ៣ ឆ្នាំខាងមុខ

ត្រូវប្រឹងប្រែងសំរេចអោយបាននូវការងារជាអាទិភាព ដូចតទៅ ៖

- រៀបចំច្បាប់អង្គការ និង លិខិតបទដ្ឋានពាក់ព័ន្ធនានា ព្រមទាំងពិនិត្យ និង កែសំរួលលិខិត បទដ្ឋាននានា ដែលមានជាធរមាន ហើយដែលពាក់ព័ន្ធនឹងប្រព័ន្ធគ្រប់គ្រងនៅតាមខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ។

- រៀបចំរចនាសម្ព័ន្ធរដ្ឋបាលឯកភាពនៅថ្នាក់ខេត្ត ក្រុង និង ស្រុក ខណ្ឌ ។

- រៀបចំប្រព័ន្ធផែនការ និង ថវិកាឯកភាពនៅថ្នាក់ខេត្ត ក្រុង ។

- បង្កើតប្រព័ន្ធគ្រប់គ្រងបុគ្គលិកនៅថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលគ្របដណ្តប់មន្ទីរជំនាញ ទាំងអស់នៅក្នុងខេត្ត ក្រុង និង ការិយាល័យនៅតាមស្រុក ខណ្ឌ ។

- បង្កើតក្រុមប្រឹក្សាខេត្ត ក្រុង និង ស្រុក ខណ្ឌ ។

- កៀងគរ និង ផ្តល់ធនធាន ទាំងក្នុងស្រុក និង ពីបរទេស សំរាប់កិច្ចអភិវឌ្ឍន៍ និង សំរាប់កសាង សមត្ថភាពរបស់រដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ។

## ២. ការគ្រប់គ្រងកម្មវិធី :

ដើម្បីសំរបសំរួល និង គាំទ្រដល់ដំណើរការកំណែទំរង់វិមជ្ឈការ និង វិសហមជ្ឈការ ប្រកប ដោយប្រសិទ្ធភាព រាជរដ្ឋាភិបាលនឹងរៀបចំកម្មវិធីជាតិមួយដូចខាងក្រោម ៖

រាជរដ្ឋាភិបាលបានបង្កើតគណៈកម្មការអន្តរក្រសួងមួយ សំដៅធានាអោយមានការ ចូលរួម ពិភាក្សាស្រុះស្រួលគ្នាពីក្នុង ចំណោមក្រសួងស្ថាប័ននានា នៃរាជរដ្ឋាភិបាលកម្ពុជា ក្នុងការរៀបចំច្បាប់អង្គការសំរាប់

គ្រប់គ្រងខេត្ត ក្រុង ស្រុក ខណ្ឌ លើមូលដ្ឋាននៃឯកសារក្របខ័ណ្ឌគោល-នយោបាយនេះ ។ គណៈកម្មការ អន្តរក្រសួងនេះ នឹងបញ្ចប់អាណត្តិរបស់ខ្លួននៅពេលដែលច្បាប់អង្គការសំរាប់គ្រប់គ្រងខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានអនុម័តប្រកាសអោយប្រើជាផ្លូវការ ។

ក្នុងល័ក្ខខ័ណ្ឌនៃច្បាប់អង្គការនឹងបង្កើតអោយមានគណៈកម្មាធិការជាតិមួយ ដើម្បីសំរបសំរួល ក្នុងការអនុវត្តច្បាប់អង្គការទាំងនេះ និង ដើម្បីផ្តល់ការណែនាំ សំរបសំរួល គាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រ វិមជ្ឈការ និង វិសហមជ្ឈការ ។

គណៈកម្មាធិការជាតិនឹងអាចបែងចែកជាអនុគណៈកម្មការនានាតាមការចាំបាច់ ដើម្បីធានា អោយមានការចូលរួមពីក្រសួង ស្ថាប័នដែលមានការពាក់ព័ន្ធផ្ទាល់ ក្នុងដំណើរការកំណែទំរង់ វិមជ្ឈការ និង វិសហមជ្ឈការ ។

ត្រូវបង្កើតអោយមាន លេខាធិការដ្ឋានមួយ ដើម្បីធ្វើជាជំនួយការឱ្យគណៈកម្មាធិការជាតិ និង អនុគណៈកម្មការនានានៃគណៈកម្មាធិការជាតិ ។ លេខាធិការដ្ឋានត្រូវរៀបចំបង្កើតអោយមានផ្នែក ការងារនានា នឹងត្រូវអនុវត្តការងារស្របតាមការដឹកនាំ ណែនាំពីគណៈកម្មាធិការជាតិ ។

ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ គឺជាអ្នកសម្របសម្រួលអោយមានគោលនយោបាយសំដៅ ធ្វើសង្គតិភាពរវាងក្រុមប្រឹក្សាកំណែទំរង់ទាំង អស់ ។

ផ្អែកតាមគោលនយោបាយខាងលើនេះ ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងកម្មវិធីជាតិ សំរាប់គាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រវិមជ្ឈការ និង វិសហមជ្ឈការ ត្រូវផ្អែកលើគោលការណ៍ដូចខាងក្រោម ÷

- គណៈកម្មាធិការជាតិ គឺជាអ្នកណែនាំគោលនយោបាយ និង

សម្របសម្រួលគាំទ្រ ការអនុវត្ត និង កៀងគរហិរញ្ញប្បទានពីប្រភព ក្នុង និង ក្រៅប្រទេស គាំទ្រដល់កម្មវិធីជាតិ សំរាប់កំណែទំរង់ វិមជ្ឈការ និង វិសហមជ្ឈការ ។

- លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជាអ្នកអនុវត្តការងារ ប្រចាំថ្ងៃ ក្រោមការដឹកនាំ ណែនាំពីគណៈកម្មាធិការជាតិ ។

អនុលោមតាមគោលនយោបាយកំណែទំរង់ខាងលើនេះ ភារកិច្ចភាគច្រើនក្នុងការគ្រប់គ្រងកិច្ច អភិវឌ្ឍន៍ និង ការផ្តល់សេវាសាធារណៈនឹងត្រូវប្រគល់ទៅអោយរដ្ឋបាលឯកភាពខេត្ត ក្រុង ស្រុក ខណ្ឌ ។ ទន្ទឹមនេះ ភារកិច្ចមួយចំនួនក៏អាចប្រគល់ត្រង់ទៅអោយឃុំ សង្កាត់ផងដែរ ។

ក្នុងការកែទំរង់ ក្រសួង ស្ថាប័ន មានភារកិច្ចសំខាន់ៗដូចខាងក្រោម÷

+ **ក្រសួងមហាផ្ទៃ** : មានភារកិច្ចចម្បងៗ ដូចតទៅ ÷

-ផ្តល់ការគាំទ្រដល់កិច្ចប្រតិបត្តិការរបស់គណៈកម្មាធិការជាតិ ដែលមានភារកិច្ចក្នុងការសំរបសំរួលនិង គាំទ្រដល់កំណែទំរង់វិមជ្ឈការវិសហមជ្ឈការ និង កំណែទំរង់នានា ដែលមានការពាក់ព័ន្ធ ។

- ត្រួតពិនិត្យនីត្យានុកូលភាពលើរាល់សេចក្តីសំរេចរបស់រដ្ឋបាលថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ ព្រមទាំងសេចក្តីសំរេចនានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

- កសាងសមត្ថភាពរបស់រដ្ឋបាលនៅតាមថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និង ក្រុមប្រឹក្សាឃុំ សង្កាត់ ។

+ **ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** : មានភារកិច្ចចម្បងៗដូចតទៅ ÷

- រៀបចំយុទ្ធសាស្ត្រវិមជ្ឈការហិរញ្ញវត្ថុ ដែលមានសង្គតិភាពជាមួយ

យុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការ និង កំណែទំរង់ហិរញ្ញវត្ថុសាធារណៈ ។

- រៀបចំគោលនយោបាយ និង លិខិតបទដ្ឋានណែនាំនានាសំរាប់គ្រប់គ្រងហិរញ្ញវត្ថុនៅតាមថ្នាក់ ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ។

- ពង្រឹងសមត្ថភាពរបស់នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន ដើម្បីផ្តល់ការគាំទ្រ និង ត្រួតពិនិត្យការ អនុវត្តកិច្ចការហិរញ្ញវត្ថុមូលដ្ឋានរបស់ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ។

+ **<u>រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ</u>**

ផ្អែកតាមក្របខ័ណ្ឌគោលនយោបាយ និង យុទ្ធសាស្ត្រកំណែទំរង់វិមជ្ឈការ វិសហមជ្ឈការ និង ច្បាប់អង្គការសំរាប់គ្រប់គ្រងខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ចាំបាច់ត្រូវរៀបចំឡើងវិញនូវការចាត់ចែងការគ្រប់គ្រង ការតែងតាំង ការតម្លើងឋានន្តរសក្តិ ការងាររៀបចំបៀវត្សក្របខ័ណ្ឌ ការលើកទឹកចិត្ត និង វិន័យរបស់មន្ត្រីរាជការតាមថ្នាក់រដ្ឋបាលនីមួយៗ ។ ដើម្បីឆ្លើយតបតាមសំណូមពរនៃការកែទំរង់នេះ ច្បាប់ លិខិតបទដ្ឋាននានា សំរាប់គ្រប់គ្រងមន្ត្រីរាជការស៊ីវិលត្រូវធ្វើការពិនិត្យកែលំអឡើងវិញ ដើម្បីអោយមាន សង្គតិភាពជាមួយគោលនយោបាយ និង យុទ្ធសាស្ត្រវិមជ្ឈការ និង វិសហមជ្ឈការ ។

+ **<u>ក្រសួង ស្ថាប័ននានា</u>** :

ក្រសួង ស្ថាប័ននានានៅថ្នាក់ជាតិ ត្រូវពង្រឹងសមត្ថភាពរបស់ខ្លួនដើម្បី ÷

- រៀបចំគោលនយោបាយតាមវិស័យអោយមានសង្គតិភាពជាមួយគោលនយោបាយជាតិស្តីពី វិមជ្ឈការ និងវិសហមជ្ឈការ និងច្បាប់អង្គការ

សំរាប់គ្រប់គ្រងខេត្តក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ។

-កសាងសមត្ថភាពគ្រប់គ្រងតាមវិស័យដល់ថ្នាក់រដ្ឋបាលនានា ។

- កំណត់និយាម និងបទដ្ឋានបច្ចេកទេសក្នុងការផ្តល់សេវា ។

- ត្រូវពិនិត្យការអនុវត្តរបស់មន្ទីរ ឬអង្គភាពជំនាញនៅតាមថ្នាក់រដ្ឋបាល និង គុណភាពនៃការ ផ្តល់សេវា ។

ផ្អែកតាម គោលការណ៍ខាងលើនេះ ការអនុវត្តកម្មវិធីជាតិនេះ មិនមែនជាបន្ទុកផ្ទាល់របស់ស្ថាប័ន ណាមួយដាច់តែម្នាក់ឯងឡើយ ហើយត្រូវអនុវត្តដោយបណ្តាក្រសួង និង ស្ថាប័នថ្នាក់ជាតិ និងមូលដ្ឋាន ។

## ៣-ការសាងភាពជាដៃគូ :

គោលការណ៍នានាដែលមានចែងក្នុងសេចក្តីថ្លែងការក្រុងរ៉ូម ស្តីពីសុខដុមនីយកម្ម នាខែកុម្ភៈ ឆ្នាំ២០០៣ និង ការប្តេជ្ញារបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្ត " សេចក្តីថ្លែងការរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ស្តីពីសុខដុមនីយកម្ម " នាខែធ្នូ ឆ្នាំ ២០០៤ គឺជាឯកសារស្នូលសំរាប់រៀបចំ និង គ្រប់គ្រងជំនួយបរទេស ដើម្បីអនុវត្តយុទ្ធសាស្ត្រវិមជ្ឈការ និង វិសហមជ្ឈការ ។

**-ការតម្រឹមជំនួយបរទេសជាមួយនឹងអាទិភាពរបស់កម្ពុជា :**

ជំនួយបរទេស សំរាប់អនុវត្ត យុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការត្រូវចូលរួមដោយផ្ទាល់ ក្នុងការអនុវត្តអោយបានសំរេច នូវការអនុវត្តយុទ្ធសាស្ត្រកំណែ ទំរង់វិមជ្ឈការ និង វិសហមជ្ឈការ ។ រាជរដ្ឋាភិបាលនឹងរៀបចំកម្មវិធីជាតិនេះ សំរាប់ជាក្របខ័ណ្ឌការងារក្នុងការរៀបចំ និងគ្រប់គ្រងជំនួយបរទេសក្នុងគោលដៅធានាអោយជំនួយបរទេសទាំងនេះ

ត្រូវបានប្រើប្រាស់ស្របនឹងបណ្តាអាទិភាពនៃកំណែទំរង់វិមជ្ឈការ និង វិសហមជ្ឈការរបស់រាជរដ្ឋាភិបាល ។

- **<u>សុខដុមនីយកម្ម</u>** : រាជរដ្ឋាភិបាលនឹងត្រូវប្រកាន់យកអភិក្រម គ្របដណ្តប់ទូទាំងកម្មវិធី ក្នុងការប្រើប្រាស់ជំនួយបរទេសសំរាប់គាំទ្រដល់ ការអនុវត្តយុទ្ធសាស្ត្រវិមជ្ឈការ និង វិសហមជ្ឈការ តាមរយៈកម្មវិធីជាតិ និង ផែនការសកម្មភាពថវិកា ។ ក្នុងន័យនេះ ការរៀបចំខាងស្ថាប័ន និង ការអនុវត្តភាពជាដៃគូ នឹងត្រូវរៀបចំដូចខាងក្រោម ÷

- រាជរដ្ឋាភិបាល នឹងបង្កើត " វេទិការាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ សំរាប់គាំទ្រវិមជ្ឈការ និង វិសហមជ្ឈការ " ។ នេះជាវេទិកាសំរាប់ពិគ្រោះ យោបល់កៀងគរធនធាន និង វាយតំលៃវឌ្ឍនភាពក្នុងការអនុវត្តកម្មវិធី ជាតិ សំរាប់អនុវត្តយុទ្ធសាស្ត្រ នៃកំណែទំរង់វិមជ្ឈការ និង វិសហមជ្ឈការ ។ វេទិកានេះក៏ជា កាលានុវត្តភាពសំរាប់ពង្រឹងភាពជាដៃគូផងដែរ ហើយ ត្រូវប្រារព្ធធ្វើឡើងយ៉ាងតិចមួយឆ្នាំម្តង ដោយអញ្ជើញ ភាគីពាក់ព័ន្ធទាំង អស់ ទាំងខាងរាជរដ្ឋាភិបាល ទាំងខាងដៃគូអភិវឌ្ឍន៍ចូលរួម ។

ទន្ទឹមនេះ រាជរដ្ឋាភិបាលនឹងរៀបចំយន្តការមួយ សំរាប់ជួយ គណៈកម្មាធិការជាតិ ក្នុងការរៀបចំវេទិកា រាជរដ្ឋាភិបាល និង ដៃគូ អភិវឌ្ឍន៍សំរាប់គាំទ្រកំណែទំរង់វិមជ្ឈការ និង វិសហមជ្ឈការ ព្រម ទាំងជួយតាមដានវាយតំលៃការផ្តល់ជំនួយខាងបច្ចេកទេស ហិរញ្ញវត្ថុ និង ការគ្រប់គ្រង ការចាត់ចែង ប្រើប្រាស់ជំនួយទាំងនេះសំរាប់កម្មវិធីជាតិ ។

នៅក្នុងការ កៀងគរការគាំទ្រទាំងនេះ ដៃគូអភិវឌ្ឍន៍អាចផ្តល់ ការគាំទ្រដល់កម្មវិធីជាតិ និង ផ្តល់ហិរញ្ញប្បទានរបស់ខ្លួនទៅក្នុងកញ្ចប់ មូលនិធិមួយ ។ ក្នុងករណីដែលដៃគូអភិវឌ្ឍន៍មិនអាចទទួលអភិក្រមនេះ

ហើយចង់រក្សាធនធានរបស់ខ្លួនសំរាប់គាំទ្រសកម្មភាពជាក់លាក់ណា មួយ នៅក្នុងផែនការសកម្មភាព ឬ តំបន់ភូមិសាស្ត្រជាក់លាក់មួយ យន្តការ នេះនឹង ពិនិត្យ និង ផ្តល់យោបល់ដើម្បីស្នើសុំការយល់ព្រមពីគណៈកម្មាធិការជាតិ ។

## ៤_ ទិធានការគ្រុខជំណាត់កាលអន្តរកាលៈ

ដើម្បីធានាអោយមានសង្គតិភាពរវាងក្របខ័ណ្ឌគោលនយោបាយ និង ក្របខ័ណ្ឌច្បាប់ គណៈកម្មការ អន្តរក្រសួង សំរាប់រៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងខេត្ត ក្រុង ស្រុក ខណ្ឌ នឹងត្រូវទទួលអាណត្តិការងារជាបន្ថែមទៀត ក្នុងការពិនិត្យពិភាក្សាឯកភាព លើសេចក្តីព្រាងឯកសារយុទ្ធសាស្ត្រស្តីពី កំណែទំរង់វិមជ្ឈការ និង វិសហមជ្ឈការ ដើម្បីស្នើសុំការអនុម័តពីរាជរដ្ឋាភិបាលកម្ពុជា ។

ក្នុងពេលដែលកំពុងរៀបចំច្បាប់អង្គការសំរាប់គ្រប់គ្រង ខេត្ត ក្រុង ស្រុក ខណ្ឌ កម្មវិធីសិលា នឹងត្រូវបន្តការងាររបស់ខ្លួនរហូតដល់ដំណាច់ឆ្នាំ ២០០៦ ហើយក្រសួងមហាផ្ទៃ នឹងត្រូវរ៉ាប់រងបន្តពីគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

កំណែទំរង់វិមជ្ឈការ និង វិសហមជ្ឈការ និង ការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងនៅថ្នាក់រដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ និង ការបន្តពង្រឹងប្រព័ន្ធគ្រប់គ្រងបច្ចុប្បន្ននៅថ្នាក់ឃុំ សង្កាត់ គឺជាដំណើរការកំណែទំរង់ដ៏ជ្រាលជ្រៅ ដែលមានផលប៉ះពាល់មកលើគ្រប់ទិដ្ឋភាពនៃការគ្រប់គ្រងនៅកម្ពុជា ។

រាជរដ្ឋាភិបាលកម្ពុជា បានធ្វើការប្តេជ្ញាចិត្តយ៉ាងមុតមាំថា នឹងជំរុញដំណើរការកំណែទំរង់នេះ ស្របតាមឯកសារគោលនយោបាយនេះ ។

ទន្ទឹមនេះ រាជរដ្ឋាភិបាលកម្ពុជាសង្ឃឹមថា គោលនយោបាយកំណែទំរង់នេះ នឹងទទួលបានការគាំទ្រ និង ចូលរួមដោយឥតសំចៃពីគ្រប់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាលពី មន្ត្រីរាជការស៊ីវិល នគរបាលជាតិ កងយោធពលខេមរភូមិន្ទ គ្រប់លំដាប់ថ្នាក់ ពីគណបក្សនយោបាយ នានា សង្គមស៊ីវិល និង ផ្នែក ឯកជន រួមទាំងប្រជាពលរដ្ឋកម្ពុជាទាំងមូល ក៏ដូចជាដៃគូអ្នកផ្តល់ជំនួយនានារបស់កម្ពុជា សំដៅនាំកម្ពុជាអោយឈានឆ្ពោះទៅរកវឌ្ឍនភាពសេដ្ឋកិច្ច និង សង្គមលើគ្រប់ផ្នែក ។

ឯកសារស្តីពី ក្របខ័ណ្ឌយុទ្ធសាស្ត្រសំរាប់កំណែទំរង់វិមជ្ឈការ និង វិសហមជ្ឈការនេះ ត្រូវបាន អនុម័តដោយរាជរដ្ឋាភិបាលកម្ពុជានៅក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៥ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៥*

KINGDOM OF CAMBODIA
NATION RELIGION KING

# ROYAL GOVERNMENT OF CAMBODIA



# STRATEGIC FRAMEWORK FOR DECENTRALIZATION AND DE-CONCENTRATION REFORMS

17 June 2005

# Table of contents

Introduction

I Present systems of management

1-Contents of the constitution..........................38

2-Current management systems at sub-national levels..39

3-General situation of management at provincial /municipal district/khan and commune/sangkat level.......39

II Vision of the Royal Government of Cambodia

1-Vision of the Royal Government of Cambodia in the formulation of management systems of province / municipality district / khan and commune/sangkat administrations ........................................42

2-Basic principles for decentralization and deconcentration reforms...........................................................44

3-Methods of reforms implementation..................45

III Decentralization and Deconcentration strategy of the Royal Government of Cambodia

1-Scope of decentralization and deconcentration strategy.....................................................45

2-Objectives and priorities of decentralization and deconcentration strategy ...............................46

3-Basic substances of Reform..............................48

4-Changes of management of sub-national administration .....................................................................................49

5-Assignment of duties and responsibilities between the different levels of administration ..56

6-Revenues and budget of provinces /municipalities districts/khans and communes/sangkats ...... 56

IV National program for The implementation of decentralization and deconcentration strategy

1-Components and Expected outputs of the national program:..........................................................58

2-Program management ....................................61

3-Parnership building .........................................64

4-Interim measures ............................................66

## Introduction

The Strategic Framework for Decentralization and De-concentration Reforms is the policy document of the Royal Government that presents the vision and the basic principles of the Royal Government that guides the process of governance reform at provincial/municipal, district/khan and commune/sangkat levels.

This policy document will identify the objectives of the national decentralization and deconcentration reforms strategy and methods to develop management structures at provincial/municipal, district/khan and commune/sangkat levels in order to achieve the objectives of decentralization and deconcentration reforms strategy.

This document will also describe the scope of the national program for the implementation of decentralization and deconcentration strategy and also the structures for the management of the program.

This document is a framework to guide all reforms affecting management systems at provincial/municipal, district/khan and commune/sangkat levels. All policies, legal instruments and operational procedures of ministries and institutions of the Royal Government relating to management, distribution of responsibilities and resources to provincial/municipal, district/khan and commune/sangkat levels must be consistent with the objectives and principles of the decentralization and deconcentration strategy in order to facilitate the development of management systems and structures. At the same time, the strategic framework is also a main document to divide the powers and the duties between the levels of administration.

## I. Present systems of management

### 1. Contents of the Constitution

According to the Constitution of the Kingdom of Cambodia, Cambodia is a unitary state. The territory of the Kingdom of Cambodia is divided into provinces and municipalities. Province is divided into districts and district is divided into communes. Municipality is divided into khans and khan is divided into sangkats. In Cambodia, there are 20 provinces, 4 municipalities, 171 districts, 14 khans, 1,510 communes and 111 sangkats.

Chapter 13, Article 146 of the Constitution of the Kingdom of Cambodia provides that " Provinces/municipalities, district khan and commune/sangkat shall be managed in accordance with an organic law." The organic law being prepared shall reflect the national decentralization and deconcentration strategy as defined in this document. The law is also a basic legal framework for the implementation of decentralization and deconcentration strategy.

**2. <u>Current management systems at sub-national levels</u>:** Currently, sub-national management systems are divided into three levels: province/municipality, district/khan and commune/sangkat.

